ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Apr-2012, 13:24
CMS/CFO: Uch Arun

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (០៨)

Case File/Dossier N°. 002/19-09-2007-ECCC-TC/SC (08)

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Motoo Noguchi
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Chandra Nihal Jayasinghe
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២
ភាសាដើម៖ ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

---

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខឆ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ

---

| ជនជាប់ចោទ៖ | សហមេធាវីការពារក្តីជនជាប់ចោទ៖ | សហព្រះរាជអាជ្ញា៖ |
|---|---|---|
| នួន ជា | សុន អរុណ | ជា លាង |
| | Michiel PESTMAN | Andrew CAYLEY |

Victor KOPPE

**<u>មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

**ពេជ អង្គ**

Elisabeth SIMONNEAU FORT

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួលបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ("ជនជាប់ចោទ")[1] ជំទាស់នឹង"សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92)"[2] ត្រង់ចំណុចដែលអង្គជំនុំជម្រះបានបដិសេធចោលសំណើសុំរបស់ជនជាប់ចោទអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[3]៖

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដែលរងការជំទាស់ *ក្នុងចំណោមនោះ* អង្គជំនុំជម្រះបានបដិសេធចោលអញ្ញត្រកម្មរបស់ជនជាប់ចោទ[4] និងសំណើសុំរបស់ជនជាប់ចោទអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរួមមួយចំពោះសំណើសុំទាំងនេះ "ដោយពិនិត្យឃើញថា សំណើទាំងនេះគឺមានភាពដូចគ្នា"[5]។

2. នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ ជនជាប់ចោទបានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដែលរងការជំទាស់ អនុលោមតាមវិធាន ៣៥(៦) នៃវិធានផ្ទៃក្នុង ជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ ការបកប្រែជាភាសាខ្មែរ ត្រូវបានជូនដំណឹងនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១[6]។

3. នៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់សារណាតបរបស់ខ្លួន[7]។

---

[1] បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E116/1/1 ("បណ្តឹងសាទុក្ខ")។

[2] ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E116 ("សេចក្តីសម្រេចដែលរងការជំទាស់")។

[3] សំណើរបស់លោក នួន ជា សុំបំពេញកិច្ចស៊ើបសួរអនុលោមតាមវិធាន ៣៥ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E 82 ("សំណើសុំអនុលោមតាមវិធាន ៣៥")

[4] អញ្ញត្រកម្មរួមបញ្ចូលគ្នា ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ 51/3 ("អញ្ញត្រកម្ម")។

[5] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ៩។

[6] អនុលោមតាមមាត្រា ៧.២ នៃសេចក្តីណែនាំស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក (អ.វ.ត.ក) អង្គជំនុំជម្រះតុលាការកំពូល បានផ្តល់ការអនុញ្ញាតឱ្យដាក់សំណៅបណ្តឹងឧទ្ធរណ៍ជាភាសាខ្មែរ "នៅក្នុងកាលៈទេសៈពិសេស"។

4. នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ជនជាប់ចោទបានដាក់ការឆ្លើយតបរបស់ខ្លួន[8]។

5. អនុលោមតាមវិធាន ១០៨(៤)(*ស្ទួន*)(ក) និងវិធាន ១០៨(២) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូល ត្រូវសម្រេចលើបណ្តឹងសាទុក្ខនេះក្នុងរយៈពេលបីខែ ក្រោយពីទទួលបាន"សំណុំរឿង រួមជាមួយនិងឯកសារថតចម្លងបញ្ជាក់ត្រឹមត្រូវនៃសេចក្តីសម្រេច និងបណ្តឹងសាទុក្ខភ្លាមៗនីមួយៗ"។ "សំណុំរឿង"រួមបញ្ចូលនូវឯកសារសម្ងាត់ដែលពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខនេះ។ ដោយសារតែឯកសារសម្ងាត់ទាំងនេះត្រូវបានទទួលត្រឹមថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១[9] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ផុតកំណត់ត្រឹមថ្ងៃ ច័ន្ទ ទី ៣០ ខែ មករា ឆ្នាំ ២០១២[10]។ ដោយអនុវត្តទៅតាមការអនុញ្ញាតនៃវិធាន ១០៨(៤)(*ស្ទួន*) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលបានចេញ"សេចក្តីសង្ខេបសំអាងហេតុ" ចំពោះសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ កាលពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២[11]។

---

[7] សារណាតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E116/1/4 ("សារណាតប")។ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតពន្យារពេលឱ្យសហព្រះរាជអាជ្ញាឆ្លើយតប (សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលដើម្បីធ្វើសារណាតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទ នួន ជា តាមវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E116/1/2/1)។

[8] ការឆ្លើយតបទៅនឹងសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E116/1/5 ("ការឆ្លើយតប")។

[9] វិធាន ១០៨(២) ផ្តល់អំណាចថា អង្គជំនុំជម្រះសាលាដំបូង ត្រូវបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះតុលាការកំពូល "ក្នុងរយៈពេល១០ ថ្ងៃ គិតពីថ្ងៃដាក់បណ្តឹងសាទុក្ខ ..."។ ថ្ងៃទី១ នៃរយៈពេលកំណត់នេះ គឺថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ដែលពេលវេលាកំណត់ "ត្រូវចាប់ផ្តើមគិតពីថ្ងៃបន្ទាប់នៃថ្ងៃជូនដំណឹងអំពីឯកសារជាភាសាខ្មែរ និងភាសាផ្លូវការមួយផ្សេងទៀតរបស់ អ.វ.ត.ក" (សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៨.៥)។

[10] ដូចទៅក្នុងករណីរឿងក្តីនេះ អនុលោមតាមវិធាន ៣៩(៣) នៃវិធានផ្ទៃក្នុង កាលបើពេលវេលាកំណត់ "ត្រូវផុតរលត់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃបុណ្យជាតិរបស់កម្ពុជា" ពេលវេលាកំណត់ត្រូវបន្តជាស្វ័យប្រវត្តិទៅថ្ងៃធ្វើការបន្ទាប់។

[11] សេចក្តីសង្ខេបអំពីសំអាងហេតុនៃសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ ឯកសារ E116/1/6 ("សេចក្តីសង្ខេប")។

6. នៅពេលនេះ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចចេញសំអាងហេតុពេញលេញចំពោះសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ខ្លួន។

## II. សេចក្ដីសម្រេចដែលរងការជំទាស់

7. សេចក្ដីសម្រេចដែលរងការជំទាស់បានដោះស្រាយទៅលើសំណើសុំ និងការជំទាស់ផ្សេងៗគ្នា ប៉ុន្តែមានមូលដ្ឋានលើកឡើងពាក់ព័ន្ធគ្នា ដោយរួមបញ្ចូលទាំងអញ្ញត្រកម្ម និងសំណើសុំរបស់ជនជាប់ចោទ ដែលអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា "ផ្នែកមួយចំនួននៃ*អញ្ញត្រកម្ម*របស់ជនជាប់ចោទដែលបានតវ៉ាអំពីសុពលភាពនៃកិច្ចស៊ើបសួរ ដោយផ្អែកលើមូលហេតុវិការៈនៅក្នុងកិច្ចដំណើរការនីតិវិធី ភាពលម្អៀង ឬការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ មិនអាចទទួលយកបាននោះទេ"[12] ពីព្រោះវិធាន ៨៩(១)(ខ) នៃវិធានផ្ទៃក្នុង ដែលត្រូវបានបកស្រាយស្របគ្នាជាមួយគ្នានឹងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនបានរួមបញ្ចូល "សុពលភាពនៃកិច្ចស៊ើបសួរ" ថាជាមូលដ្ឋានសម្រាប់រំលត់បណ្ដឹងអាជ្ញានៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនោះទេ[13]។ បន្ថែមពីលើនេះ លក្ខខណ្ឌចាំបាច់សម្រាប់សម្រេចឱ្យបញ្ចប់ ឬបង្អង់កិច្ចដំណើរការនីតិវិធីដែលត្រូវបានបង្កើតនៅកម្រិតអន្តរជាតិ គឺមានលក្ខណៈ"ខ្ពស់បំផុត" ហើយជនជាប់ចោទមានឱកាសជាច្រើនរួចមកហើយ ក្នុងការជំទាស់ទៅនឹងកិច្ចស៊ើបសួរនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ[14]។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលសំណើរបស់ជនជាប់ចោទសុំបង្អង់ ឬបញ្ចប់កិច្ចដំណើរការនីតិវិធី ដែលបានរួមបញ្ចូលនៅក្នុងអញ្ញត្រកម្មរបស់ខ្លួន។

8. សេចក្ដីសម្រេចដែលរងការជំទាស់ ក៏បានបដិសេធចោលទាំងស្រុងចំពោះសំណើសុំអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ផងដែរ។ ការលើកឡើងផ្នែកអង្គហេតុដែលមាននៅក្នុងសំណើសុំអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង មានភាគច្រើនស្រដៀងគ្នានឹងការលើកឡើងនៅក្នុងផ្នែកអញ្ញត្រកម្ម ដែលបានលើកឡើងខាងលើ ហើយភាពខុសគ្នាអាចបង្ហាញឱ្យឃើញរវាង (i) អំណះអំណាងដែលទាក់ទងផ្ទាល់នឹងសំណុំរឿង ០០២ និង (ii) អំណះអំណាងដែលទាក់ទងផ្ទាល់

[12] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៧ (សេចក្ដីបញ្ជាក់បន្ថែម)។

[13] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៦-១៧។

[14] សេចក្ដីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៨។

00803363



នឹងសំណុំរឿង ០០៣ និង ០០៤។ អំណះអំណាងដែលទាក់ទងផ្ទាល់នឹងសំណុំរឿង ០០៣ និង ០០៤ ត្រូវបានលើកឡើងដោយជនជាប់ចោទថា មានផលប៉ះពាល់ដោយផ្ទាល់ចំពោះភាពត្រឹមត្រូវនៃសំណុំរឿង ០០៣ និង ០០៤ ឬមានផលប៉ះពាល់ដោយប្រយោលចំពោះភាពត្រឹមត្រូវនៃសំណុំរឿង ០០២។ ទាក់ទងនឹងអំណះអំណាងដែលទាក់ទងដោយផ្ទាល់ទៅនឹងសំណុំរឿង ០០៣ និង ០០៤ អង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេចចំពោះផលប៉ះពាល់លើសំណុំរឿង ០០៣ និង០០៤ ទេ ដោយសាររឿងក្តីទាំងនេះ កំពុងស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរ ដូច្នេះ ស្ថាប័នដែលមានសមត្ថកិច្ចនោះ គឺសហចៅក្រមស៊ើបអង្កេត ហើយបន្ទាប់មក ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ គឺអង្គបុរេជំនុំជម្រះ[15]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការលើកឡើងដូចគ្នាទាំងនេះដែលទាក់ទងដោយផ្ទាល់នឹងសំណុំរឿង ០០៣ និង ០០៤ មិនមាន“ផលប៉ះពាល់ជាក់ស្តែង [...] លើភាពត្រឹមត្រូវកិច្ចដំណើរការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង ០០២”[16] នោះទេ។ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធចោលទាំងស្រុងចំពោះសំណើសុំអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងរបស់ជនជាប់ចោទ ប៉ុន្តែមិនបានលើកឡើងឲ្យច្បាស់ចំពោះការចោទប្រកាន់ផ្នែកអង្គហេតុដែលទាក់ទងដោយផ្ទាល់ទៅនឹងសំណុំរឿង ០០២ នោះទេ។

## III. **សារណា**

ក. <u>បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ</u>

9. បណ្តឹងសាទុក្ខ បានលើកឡើងសាជាថ្មីអំពីការជ្រៀតជ្រែកនយោបាយអូសបន្លាយយ៉ាងយូរ និងកំពុងតែបន្តជ្រៀតជ្រែកមកក្នុងកិច្ចការរបស់ អ.វ.ត.ក ដែលបង្កើតបានជាមូលដ្ឋាននៃសំណើសុំពាក្យសុំ និងបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ដែលត្រូវបានដាក់ចាប់ពីខែមីនា ឆ្នាំ ២០០៩[17]។ ការចោទប្រកាន់ផ្នែកអង្គហេតុស្តីអំពីការជ្រៀតជ្រែកចូលកិច្ចការតុលាការរបស់ជនជាប់ចោទ មានសេចក្តីសង្ខេបដូចខាងក្រោម៖

---

[15] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១។

[16] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១។

[17] បណ្តឹងសាទុក្ខ កថាខណ្ឌ ២។

ក. អ.វ.ត.ក ត្រូវបានសង្ស័យចំពោះអំពើពុករលួយ ដែលមានលក្ខណៈរាលដាលយ៉ាងទូលំទូលាយ និងនៅតែបន្ត ដែលត្រូវបានមើលឃើញ តាមរយៈការជំរិតទាប្រាក់ពីបុគ្គលិកដែលលេចឡើងកាលពីពេលជាងបួនឆ្នាំមុន[18]។

ខ. នៅខែ កក្កដា ឆ្នាំ ២០០៩ លោក គង់ សំអុល រដ្ឋមន្ត្រីអមព្រះបរមរាជវាំងនៃរាជរដ្ឋាភិបាលកម្ពុជា បានបដិសេធលិខិតដែលបានផ្ញើពីការិយាល័យសហចៅក្រមស៊ើបអង្កេតទៅកាន់ព្រះបិតាជាតិ នរោត្តម សីហនុ ដែលខ្លឹមសារក្នុងលិខិតនោះមានបំណងកោះអញ្ជើញព្រះរាជបិតាជាតិក្នុងឋានៈជាសាក្សី ទាក់ទងនឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០២[19]។

គ. នៅខែ កញ្ញា ឆ្នាំ ២០០៩ លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានប្រកាសជាសាធារណៈនៅខេត្ត តាកែវ ដែលជាការជ្រៀតជ្រែកទៅនឹងដីកាកោះដើម្បីស្តាប់ចម្លើយមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជាចំនួនប្រាំមួយរូប ("មន្ត្រីប្រាំមួយរូប") ដែលពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតលើសំណុំរឿង ០០២[20]។

ឃ. នៅខែ តុលា ឆ្នាំ ២០០៩ អស់រយៈពេលពីរសប្តាហ៍បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតបានចេញដីកាកោះហៅមន្ត្រីប្រាំមួយរូបក្នុងអំឡុងពេលស៊ើបសួរនៅក្នុងសំណុំរឿង ០០២ សារព័ត៌មាននានាបានរាយការណ៍ថា លោក ខៀវ កាញារីទ្ធ អ្នកនាំពាក្យរបស់រាជរដ្ឋាភិបាលបានលើកឡើងថា ទោះបីជាមន្ត្រីប្រាំមួយរូប បង្ហាញខ្លួននៅតុលាការដោយស្ម័គ្រចិត្តក៏ដោយ ក៏ជំហររបស់រាជរដ្ឋាភិបាលគឺថា មន្ត្រីទាំងនោះមិនគួរផ្តល់សក្ខីកម្មនោះទេ។ គាត់បានបន្ថែមថា មន្ត្រីបរទេសដែលបម្រើការនៅតុលាការនេះ អាច "វេចបង្វិចរបស់ពួកគេ ហើយត្រលប់ទៅផ្ទះវិញ" ប្រសិនបើមិនពេញចិត្តជាមួយនឹងការសម្រេចនេះ។ ជនជាប់ចោទ នៅតែលើកឡើងថា ជំហររបស់រាជរដ្ឋាភិបាលបាននាំឲ្យមានការបរាជ័យដល់ការកោះហៅមន្ត្រីប្រាំមួយរូប ដោយផ្ទាល់ ឬដោយប្រយោល[21]។

---

[18] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣(ក)។

[19] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣(ខ)។

[20] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣(គ)។

[21] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣(គ)។ *សូមមើលផងដែរ* បណ្តឹងសាទុក្ខ កថាខណ្ឌ៤ (ដកស្រង់ចេញពីមតិយោបល់របស់ចៅក្រម Catherine Marchi-Uhel និង Rowan Downing ដែលភ្ជាប់ទៅនឹង សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង

ង. ទាក់ទងនឹងសំណុំរឿង ០០៣ និង ០០៤ សមាជិកមួយចំនួនរបស់រាជរដ្ឋាភិបាល បានលើកឡើងម្តងហើយម្តងទៀត អំពីការជំទាស់របស់រាជរដ្ឋាភិបាលចំពោះសំណុំរឿង ០០៣ និង ០០៤។ រាជរដ្ឋាភិបាល ក៏បានលើកឡើងថា មន្ត្រីអ.វ.ត.ក គួរតែចូលរួម "នៅក្នុងការអនុវត្តរបៀបវារៈតុលាការដែលបានជំរុញដោយហេតុផលនយោបាយ"[22]។

ច. ជនជាប់ចោទក៏បានកត់សម្គាល់ថា អង្គការយុត្តិធម៌សង្គមសេរី បានចោទសួរអំពីឯករាជភាពរបស់សហចៅក្រមស៊ើបអង្កេត និងបានអំពាវនាវចំនួនពីរដង ស្នើសុំឱ្យអង្គការសហប្រជាជាតិធ្វើការស៊ើបអង្កេតអំពីឯករាជភាពចំពោះការចោទប្រកាន់ ទាក់ទងនឹងការរារាំងសំណុំរឿង ០០៣ និង ០០៤។ អ្នកសង្កេតការណ៍ខាងក្រៅ បានរិះគន់ម្តងហើយម្តងទៀតអំពី "ការបន្តគាំទ្រដល់របៀបវារៈរបស់រដ្ឋាភិបាល"[23]។ ប្រធានគណៈមេធាវីអន្តរជាតិ បានអះអាងថា ភាពជឿជាក់របស់អ.វ.ត.ក ត្រូវបានបាត់បង់តម្លៃតាមរយៈរបាយការណ៍ និងការចោទប្រកាន់ចំពោះការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាល និងជាបច្ច័យ "ខកខានមិនបានបំពេញទៅនឹងបទដ្ឋានអន្តរជាតិស្តីពីភាពត្រឹមត្រូវ"[24]។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានអំពាវនាវឱ្យសហចៅក្រមស៊ើបអង្កេតទាំងពីររូបលាលែងចេញពីដំណែង ដោយផ្អែកលើមូលដ្ឋានថា សហចៅក្រមស៊ើបអង្កេតទាំងពីររូប បានរំលោភបំពានលើតួនាទីផ្លូវច្បាប់ និងវិជ្ជាជីវៈរបស់ខ្លួន។ រដ្ឋមន្ត្រីការបរទេសនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានដកស្រង់សម្តីដែលគាត់បានមានប្រសាសន៍ថា "មានតែកម្ពុជាទេ ទើបអាចសម្រេចថាតើជនសង្ស័យប៉ុន្មាននាក់បន្ថែមទៀត ដែលសាលាក្តីខ្មែរក្រហមនឹងធ្វើការចោទប្រកាន់នោះ"[25] និងការលាលែងពី

សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D314/1/12 ("មតិភាគតិច អ.ប.ជ") កថាខណ្ឌ ៦, ៨)។

[22] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣(ឃ)។

[23] បណ្តឹងសាទុក្ខ កថាខណ្ឌ ៥។

[24] បណ្តឹងសាទុក្ខ កថាខណ្ឌ ៦ (ដកស្រង់ចេញពីអត្ថបទបោះពុម្ពផ្សាយរបស់ Mark Ellis *គណៈមេធាវីអន្តរជាតិ* "ការធានាចំពោះឯករាជ្យភាពតុលាការនៅក្នុងតុលាការចម្រុះ៖ មេរៀនដែលបានមកពី អ.វ.ត.ក និងការអនុវត្តជាក់ដ៏ប្រសើរបំផុតសម្រាប់អនាគត" ចុះខែ កញ្ញា ឆ្នាំ ២០១១ ទំព័រ ៤៦។

[25] បណ្តឹងសាទុក្ខ កថាខណ្ឌ ៩។

មុខតំណែងរបស់ចៅក្រម Blunk អាច "ត្រូវបានគេយល់ថា ជាការចុះចាញ់ដោយសារតែការដាក់សម្ពាធពីអ្នកសង្កេតការណ៍អន្តរជាតិ"[26]។

10. បណ្តឹងសាទុក្ខបានលើកឡើងទឡ្ហីករណ៍ចំនួនបួន ដើម្បីស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល បដិសេធចោលសេចក្តីម្រេចដែលរងការជំទាស់នេះ និងប្រើប្រាស់អំណាចទូលំទូលាយរបស់ខ្លួន ផ្អែកតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង ដើម្បីបង្គាប់ឱ្យមានស្ថាប័នតុលាការឯករាជ្យមួយ ក្នុងការធ្វើការស៊ើបសួរជាសាធារណៈដើម្បីបំពេញកិច្ចស៊ើបសួរ មុនពេលសវនាការលើអង្គសេចក្តី នៅក្នុងសំណុំរឿង ០០២។ បណ្តឹងសាទុក្ខក៏បានស្នើសុំឱ្យមានសវនាការជាសាធារណៈផងដែរ[27]។

11. បើតាមទឡ្ហីករណ៍ទីមួយនៃបណ្តឹងសាទុក្ខ ជនជាប់ចោទបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយសារមិនបានផ្តល់មូលដ្ឋានដែលមានសំអាងហេតុក្នុងការបដិសេធចោលការទាមទាររបស់ជនជាប់ចោទ ទាក់ទងដោយផ្ទាល់នឹងសំណុំរឿង ០០២ ទោះបីជាការទាមទារត្រូវបានរួមបញ្ចូលនៅក្នុងសំណើសុំអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងក្តី។ ហេតុដូច្នេះ សេចក្តីសម្រេចដែលរងការជំទាស់ បានបំពារបំពានគោលការណ៍ដែលថា ដីកាសម្រេច និងសេចក្តីសម្រេច ត្រូវតែមានសំអាងហេតុគ្រប់គ្រាន់[28]។

12. ទីពីរ ការលើកឡើងទាក់ទងនឹងសំណុំរឿង ០០៣ និង ០០៤ ត្រូវបានបដិសេធចោលដោយផ្អែកលើមូលដ្ឋាននៃការសន្មតដោយមិនត្រឹមត្រូវដែលថា អង្គជំនុំជម្រះសាលាដំបូងអាចបំពេញតួនាទីស្របតែតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងតែប៉ុណ្ណោះ ទាក់ទងនឹងបញ្ហានៅចំពោះមុខ។ ការបកស្រាយនេះគឺជាការបកស្រាយដែលមានលក្ខណៈ "ផ្លូវច្បាប់" និង "ផ្លូវការ" ហួសហេតុ ហើយផ្ទុយទៅនឹងពាក្យពេចន៍ដ៏ទូលំទូលាយនៃបទប្បញ្ញត្តិនេះ និងលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិនេះ ដែលមានគោលបំណងធានាសុចរិតភាពនៃដំណើរការនីតិវិធី និងរារាំងការជ្រៀតជ្រែកដែលអាចកើតមាន[29]។ បណ្តឹង

---

[26] បណ្តឹងសាទុក្ខ កថាខណ្ឌ ១០។

[27] បណ្តឹងសាទុក្ខ កថាខណ្ឌ ៤១។

[28] បណ្តឹងសាទុក្ខ កថាខណ្ឌ ១២, ២៤។

[29] បណ្តឹងសាទុក្ខ កថាខណ្ឌ ២៥-២៨ (ដកស្រង់ចេញពីសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D314/2/7)។

សាទុក្ខលើកឡើងបន្ថែមថា អង្គជំនុំជម្រះសាលាដំបូងមិនត្រូវបានហាមឃាត់ក្នុងការដោះស្រាយករណីជ្រៀតជ្រែកដែលបានកើតឡើងនៅក្នុងអំឡុងពេលកិច្ចស៊ើបសួររបស់តុលាការទេ "ប្រសិនបើការជ្រៀតជ្រែកបែបនេះ (ក) មានលក្ខណៈច្បាស់លាស់ ជាលើកដំបូងនៅក្នុងដំណាក់កាលជំនុំជម្រះ ឬ (ខ) ដូចនៅក្នុងករណីពេលនេះ មិនត្រូវបានធ្វើចំណាត់ការដោយសមស្របពី ក.ស.ច.ស និង/ឬ អង្គបុរេជមនុំជម្រះ"[30]។ យោងតាមបណ្តឹងសាទុក្ខ ការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងថា ការចោទប្រកាន់ដែលបានលើកឡើងនៅពេលនេះ គួរត្រូវបានដោះស្រាយយ៉ាងត្រឹមត្រូវដោយសហចៅក្រមស៊ើបអង្កេត និង/ឬអង្គបុរេជំនុំជម្រះ គឺជា "ការលើកឡើងដោយខ្វះការពិចារណាយ៉ាងច្បាស់" និង"នឹងមានន័យស្មើនឹងការអនុវត្តដែលមិនទទួលបានផ្លែផ្កា" ដោយសារតែគោលជំហរកាលពីមុនរបស់សហចៅក្រមស៊ើបអង្កេត ការសង្ស័យថាបានពាក់ព័ន្ធនឹងការចោទប្រកាន់នៃការជ្រៀតជ្រែករបស់រដ្ឋាភិបាល និងការកត់សម្គាល់របស់ពួកគេចំពោះភាពមិនសក្តិសមតាមវិជ្ជាជីវៈ[31]។ បន្ថែមពីលើនេះ វិធាន ៣៥ នៃវិធានផ្ទៃក្នុង មិនបានចែងអំពីលក្ខខណ្ឌតម្រូវនៃ"ព្យសនកម្មជាក់ស្តែង"ណាមួយ ចំពោះជនជាប់ចោទ ឬ"ផលប៉ះពាល់ជាក់ស្តែង"ណាមួយទៅលើកិច្ចដំណើរការនីតិវិធីឡើយ[32]។ ដូច្នេះ ជនជាប់ចោទលើកឡើងថា ការខកខានទាំងអស់នេះចាត់ទុកថា ជាកំហុស អង្គច្បាប់ដែលនាំឲ្យមោឃៈសេចក្តីសម្រេចដែលរងការជំទាស់[33]។

13. ទីបី ជនជាប់ចោទអះអាងថា អង្គជំនុំជម្រះសាលាដំបូងមិនបានវាយតម្លៃភស្តុតាងនានាដែលទាក់ទងនឹងសំណុំរឿង ០០៣ និង ០០៤ រួមជាមួយនឹងសេចក្តីអះអាងពីសំណុំរឿង ០០២ ដែលជាភស្តុតាងពាក់ព័ន្ធទៅនឹងការបំភ្លឺ"បរិបទលើសលុប" និងការបង្ហាញពី"លំនាំដែលមានចេតនាគិតទុកជាមុន"នៃការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាល[34]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តនូវការភ័ន្តច្រឡំដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ[35]។

---

[30] បណ្តឹងសាទុក្ខ កថាខណ្ឌ ២៩។

[31] បណ្តឹងសាទុក្ខ កថាខណ្ឌ ២៩។

[32] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣០។

[33] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣១។

[34] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៣-៣៤។

[35] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣២។

14. មូលដ្ឋានទីបួននៃបណ្តឹងសាទុក្ខ៖ អង្គជំនុំជម្រះសាលាដំបូង ភ័ន្តច្រឡំលើអង្គច្បាប់ តាមរយៈការលើកឡើងថា ភាគីនានា មិនអាចផ្តួចផ្តើមឲ្យបំពេញកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ៣៥ តាមការស្នើសុំរបស់ខ្លួន ដោយផ្អែកតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលត្រូវបានកែប្រែនាពេលបន្ទាប់ក្រោយមក[36]។ បណ្តឹងសាទុក្ខទទួលស្គាល់ថា សេចក្តីសម្រេចដែលរងការជំទាស់ មិនបានបដិសេធសំណើសុំអនុលោមតាមវិធាន៣៥ ដោយផ្អែកតាមមូលដ្ឋាននេះទេ ប៉ុន្តែបណ្តឹងសាទុក្ខ ស្នើសុំថា អង្គជំនុំជម្រះតុលាការកំពូល ដោះស្រាយបញ្ហាអង្គច្បាប់ដើម្បីលើកកម្ពស់ការបកស្រាយវិធាន៣៥ឲ្យបានត្រឹមត្រូវ[37]។

ខ. សារណាតបរបស់សហព្រះរាជអាជ្ញា

15. សហព្រះរាជអាជ្ញាលើកទឡ្ហីករណ៍ថា ទឡ្ហីករណ៍ទីមួយ និងទីបួននៃបណ្តឹងសាទុក្ខ មិនអាចទទួលយកបានទេ ដោយសារតែទឡ្ហីករណ៍ទាំងនេះ សុទ្ធតែមិនមានមូលដ្ឋានផ្អែកអង្គហេតុនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់។ លើសពីនេះ ទឡ្ហីករណ៍ទីបួននៃបណ្តឹងសាទុក្ខ"ហាក់ដូចជាមានចេតនាបកស្រាយមិនត្រឹមត្រូវ"ចំពោះហេតុផលរបស់អង្គជំនុំជម្រះសាលាដំបូង[38]។ សហព្រះរាជអាជ្ញាលើកឡើងបន្ថែមថា ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាំងអស់នេះ គឺមិនមានមូលដ្ឋាននោះទេ និងស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឲ្យធ្វើការសម្រេច ដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ[39]។

16. ទាក់ទិននឹងទឡ្ហីករណ៍ទីមួយនៃបណ្តឹងសាទុក្ខ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាត្រឹមត្រូវទៅនឹងការចោទប្រកាន់ក្នុងសំណុំរឿង ០០២។ អំណះអំណាងទាំងនេះ ត្រូវបានសង្ខេប ហើយអង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោល ដោយសារភាពមិនអាចទទួលយកបាន ដែលត្រូវបានសម្រេចយោងតាមផលប្រយោជន៍សេដ្ឋកិច្ច និងប្រសិទ្ធភាព

---

[36] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៥។

[37] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៥។

[38] សារណាតប កថាខណ្ឌ ១០។

[39] សារណាតប កថាខណ្ឌ ៤, ៤៤។

ក្នុងការមិនពិចារណាឡើងវិញចំពោះការចោទប្រកាន់ដែលត្រូវបានវាយតម្លៃ ដើម្បីដោះស្រាយផ្នែកទាំងឡាយនៃអញ្ញត្រកម្មរបស់ជនជាប់ចោទ ទាក់ទងនឹងការជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការ[40]។

17. ចំពោះមូលដ្ឋានទីពីរ ជំហររបស់សហព្រះរាជអាជ្ញា គឺថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសអង្គច្បាប់ដែលធ្វើឱ្យសេចក្តីសម្រេចដែលរងការជំទាស់មោឃៈ ក្នុងការសម្រេចថា សំណើសុំអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ត្រូវតែ (ក) ជាប់ពាក់ព័ន្ធនឹងបញ្ហាដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលយក ហើយ(ខ) ត្រូវបង្ហាញផលប៉ះពាល់ជាក់ស្តែងទៅលើភាពត្រឹមត្រូវនៃដំណើរការនីតិវិធី។ ការលើកឡើងអំពីបទដ្ឋានស្តីពីភស្តុតាងដែលមានចែងនៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង គឺស៊ីសង្វាក់គ្នាទៅនឹងពាក្យពេចន៍ ព្រមទាំងគោលបំណងនៃសេចក្តីសម្រេចបែបនោះ[41]។

18. យោងតាមទឡ្ហីករណ៍ទីបីនៃបណ្តឹងសាទុក្ខ សារណាតបរបស់សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង“បានដឹងច្បាស់”ចំពោះការចោទប្រកាន់ទាំងអស់ ដែលរួមបញ្ចូលទាំងសំណើសុំអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែលត្រូវបានបង្ហាញដោយអង្គហេតុដែលលើកឡើងថា ដំបូង ការចោទប្រកាន់ទាំងនោះត្រូវបានសង្ខេប និងបន្ទាប់មកត្រូវបានពិចារណាដើម្បីផ្ទុះបញ្ចាំងការចោទប្រកាន់ទាំងឡាយដែលមាននៅក្នុងអញ្ញត្រកម្ម និងជាចុងក្រោយបានដោះស្រាយតាមមធ្យោបាយនៃសំអាងហេតុផ្លូវច្បាប់[42]។ ហេតុដូច្នេះ ជនជាប់ចោទមិនបានបង្ហាញអំពីការរំលោភបំពានឆន្ទានុសិទ្ធិ ឬការធ្វើឱ្យខូចប្រយោជន៍ដល់សិទ្ធិរបស់ជនជាប់ចោទនោះទេ[43]។

19. សហព្រះរាជអាជ្ញាលើកឡើងថា ទឡ្ហីករណ៍ទីបួននៃបណ្តឹងសាទុក្ខមិនអាចទទួលយកបាន ដោយសារតែមូលដ្ឋាននេះ មិនមានមូលដ្ឋានអង្គហេតុនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ ដែល “មិនអាចត្រូវបានយល់ថា ជាការហាមឃាត់ភាគីណាមួយមិនឱ្យស្នើសុំស្ថាប័នតុលាការមានសមត្ថកិច្ចណាមួយ ដើម្បីកុំឱ្យមានការបើកកិច្ចស៊ើបអង្កេត អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង

[40] សារណាតប កថាខណ្ឌ ១១-១៣។

[41] សារណាតប កថាខណ្ឌ ៣១។

[42] សារណាតប កថាខណ្ឌ ៣៨។

[43] សារណាតប កថាខណ្ឌ ៣៥, ៣៨។

នោះទេ"[44]។ ប្រសិនបើអាចទទួលយកបាន ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខនេះ គួរតែត្រូវបានបដិសេធចោលដោយសារមិនមានមូលដ្ឋានគ្រប់គ្រាន់ ពីព្រោះតែ"មិនមានការជាប់ទាក់ទងដោយសមហេតុផលទៅនឹងចំណុចច្បាប់ដែលបានលើកឡើង នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់"[45]។ ទោះបីជាអង្គជំនុំជម្រះយោងមិនត្រឹមត្រូវណាមួយទៅលើសេចក្តីសម្រេច ដែលក្រោយមកត្រូវបានពិនិត្យឡើងវិញក្តី ជនជាប់ចោទមិនបានបង្ហាញឲ្យឃើញថា កំហុសបែបនេះបានធ្វើឲ្យមោឃៈដល់សេចក្តីសម្រេចដែលរងការជំទាស់នោះទេ[46]។

20. សារណាតបលើកឡើងថា បណ្តឹងសាទុក្ខផ្អែកលើព្រឹត្តិការណ៍ សេចក្តីថ្លែងការណ៍ និងឯកសារជាច្រើនដែលមិនមានចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅពេលដែលចេញសេចក្តីសម្រេចដែលរងការជំទាស់ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលគួរបដិសេធចោលនូវឯកសារទាំងនេះ[47]។ ជាចុងក្រោយ ដំណោះស្រាយដែលបានស្នើសុំឱ្យបើកកិច្ចស៊ើបអង្កេតដោយស្ថាប័នតុលាការ*ខាងក្រៅ* ពុំស្ថិតក្នុងវិសាលភាពនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុងឡើយ[48]។

គ. <u>ការឆ្លើយតបរបស់ជនជាប់ចោទ</u>

21. នៅក្នុងការឆ្លើយតប ជនជាប់ចោទអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចពិចារណាសំណើសុំអញ្ញត្រកម្មអនុលោមតាមវិធាន ៣៥ របស់ខ្លួន ដោយឯករាជ្យ ពីព្រោះអញ្ញត្រកម្មត្រូវបានធ្វើឡើងអនុលោមតាមបទប្បញ្ញត្តិខុសៗគ្នា ដែលលើកឡើងអំពីបញ្ហាច្បាប់ដោយឡែកពីគ្នា[49]។ ការឆ្លើយតប ក៏បានអះអាងផងដែរថា អង្គជំនុំជម្រះតុលាការកំពូលមិនត្រូវបានរារាំងពីការពិចារណាលើភស្តុតាងថ្មីនោះទេ ទោះបីជាភស្តុតាងនោះមិនមាននៅចំពោះអង្គជំនុំជម្រះសាលាដំបូង ក្នុងពេលអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចដែលរងការជំទាស់នេះ និងនៅពេលមានការ

[44] សារណាតប កថាខណ្ឌ ១៥។

[45] សារណាតប កថាខណ្ឌ ៣៣។

[46] សារណាតប កថាខណ្ឌ ៣៣។

[47] សារណាតប កថាខណ្ឌ ៣៩។

[48] សារណាតប កថាខណ្ឌ ៤០។

[49] ការឆ្លើយតប កថាខណ្ឌ ២។

ស្នើសុំនៅក្នុងបណ្តឹងសាទុក្ខនោះ ដែលជា"ការស៊ើបអង្កេតប្រកបដោយឯករាជ្យ"[50] គឺស្ថិតនៅក្នុងវិសាលភាពនៃវិធាន ៣៥(២)(គ) នៃវិធានផ្ទៃក្នុង[51]។

ឃ. <u>បញ្ហាស្តីពីការបំពារបំពានលើភាពសម្ងាត់នៃឯកសារ</u>

22. សហមេធាវីរបស់ជនជាប់ចោទ ("មេធាវីការពារក្តី") បានប្រកាន់ជំហរថា ការលើកឡើងរបស់ខ្លួននៅក្នុងបណ្តឹងសាទុក្ខនេះ គប្បីចាត់ចំណាត់ថ្នាក់ជាឯកសារសាធារណៈ និង "នៅក្នុងកាលៈទេសៈណាក៏ដោយ មេធាវីការពារក្តីនឹងចាត់ទុកឯកសារនេះ ជាឯកសារសាធារណៈ"[52]។ ទាក់ទងបញ្ហានេះ មេធាវីការពារក្តីកត់សម្គាល់ថា សារណាទាំងនេះមិនបានបង្ហាញផ្នែកណាមួយនៃសេចក្តីសម្រេចដែលរងការជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកោសលុប ឬក៏ឯកសារណាមួយ ដែលមិនទាន់បានផ្សព្វផ្សាយទូលំទូលាយដោយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននោះទេ។ បន្ថែមពីលើនេះទៀត ការដាក់ជាសម្ងាត់លើបញ្ហាដែលមានសារសំខាន់ជាសាធារណៈ និងជាស្ថាប័ន នឹងនាំឱ្យមានការជ្រៀតជ្រែកចូលក្នុងដំណើរការនីតិវិធីដែលត្រឹមត្រូវ និងមានតម្លាភាព[53]។

23. សារណាតបកត់សម្គាល់ថា បណ្តឹងសាទុក្ខហាក់ដូចជាត្រូវបានបង្ហាញឱ្យឃើញថា បានរំលោភលើការចាត់ចំណាត់ថ្នាក់ឯកសាររបស់អង្គជំនុំជម្រះតុលាការកំពូល ជាឯកសារសម្ងាត់ ដូច្នេះហើយ សូមស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលប្រើយុត្តាធិការបន្ទាប់បន្សំក្រោមវិធាន ៣៥ ដើម្បីធ្វើការស៊ើបអង្កេត *តាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន* ទៅលើការជ្រៀតជ្រែក ដោយ"ចាត់វិធានការណាមួយដែលអង្គជំនុំជម្រះ យល់ថាសមស្របដើម្បីគាំទ្រដល់សុចរិតភាពនៃដំណើរការនីតិវិធីស៊ើបសួរ"[54]។ មេធាវីការពារក្តីលើកឡើងថា មេធាវីការពារក្តីបានចែកចាយបណ្តឹងសាទុក្ខនេះ

---

[50] ការឆ្លើយតប កថាខណ្ឌ ៤។

[51] ការឆ្លើយតប កថាខណ្ឌ ៣(ខ) និង(គ)។

[52] បណ្តឹងសាទុក្ខ កថាខណ្ឌ ១ និងជើងទំព័រលេខ ៤។ ការឆ្លើយតប កថាខណ្ឌ ១។

[53] បណ្តឹងសាទុក្ខ កថាខណ្ឌ ១ និងជើងទំព័រលេខ ៤។ ការឆ្លើយតប កថាខណ្ឌ ១។

[54] សារណាតប កថាខណ្ឌ ៤១-៤៤។

ទៅឲ្យ"សមាជិកនានារបស់សារព័ត៌មានក្នុងស្រុក និងអន្តរជាតិ"[55] ដោយសារតែប្រការនេះស្រប ទៅនឹងច្បាប់កម្ពុជា ផលប្រយោជន៍យុត្តិធម៌ និងការការពារសិទ្ធិរបស់ជនជាប់ចោទ[56]។

## IV. បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខឆ្លាមៗ

24. អនុលោមតាមវិធាន ១០៤(១) និង ១០៥(២) នៃវិធានផ្ទៃក្នុង បណ្តឹងសាទុក្ខភ្លាមៗអាចផ្អែកទៅលើ មូលដ្ឋានមួយ ឬលើសពីមួយក្នុងចំណោមមូលដ្ឋានបីខាងក្រោមនេះ ៖

- កំហុសលើអង្គច្បាប់ ដែលនាំឲ្យមោឃៈសេចក្តីសម្រេច
- កំហុសលើអង្គហេតុ ដែលនាំឲ្យសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះមាន ភាពមិនយុត្តិធម៌ និង
- កំហុសដែលស្តែងឡើងពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យ មានការប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។

25. ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់រួចហើយ មូលដ្ឋានទាំងបីនៃបណ្តឹងសាទុក្ខ "ត្រូវ តែអានផ្តាច់ចេញពីគ្នា" ដែលមានន័យថា ដើម្បីឲ្យមូលដ្ឋានទីមួយ និងមូលដ្ឋានទីពីរ អាចទទួល យកបាន ម្ចាស់បណ្តឹងសាទុក្ខមិនតម្រូវឲ្យបង្ហាញថា កំហុសដែលត្រូវបានលើកឡើងនេះបណ្តាល ឲ្យប៉ះពាល់ដល់សិទ្ធិរបស់ខ្លួននោះឡើយ[57]។

---

[55] ការឆ្លើយតប កថាខណ្ឌ ៦។

[56] ការឆ្លើយតប កថាខណ្ឌ ៦-៧។

[57] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E50/3/1/4 កថាខណ្ឌ ២០។

## V. ផ្នែកសំអាងហេតុ

### ក. ភាពអាចទទួលយកបាន

26. បណ្តឹងសាទុក្ខអាចទទួលយកបានអនុលោមតាមវិធាន ៣៥(៦) និង ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង និងត្រូវបានដាក់ចូលក្នុងសំណុំរឿងតាមពេលកំណត់។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធសំណើសុំឲ្យមានសវនាការផ្ទាល់មាត់។

### ខ. មូលដ្ឋានទីមួយសម្រាប់បណ្តឹងសាទុក្ខ

27. វិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែលដោះស្រាយចំពោះការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ និងវិធាន ៨៩ នៃវិធានផ្ទៃក្នុង ដែលបញ្ញត្តិអំពីអញ្ញត្រកម្ម គឺជាបទប្បញ្ញត្តិពីរផ្សេងគ្នា ដែលមានលក្ខណៈខុសគ្នានៅត្រង់ចំណុចជាច្រើន ដូចជា ស្ថានភាពដែលវិធាននេះត្រូវដោះស្រាយ យន្តការនីតិវិធីដែលត្រូវអនុវត្តតាម ស្ថាប័នតុលាការដែលមានអំណាចក្នុងការវិនិច្ឆ័យ និងគួរឲ្យកត់សម្គាល់បំផុតនោះ គឺបទដ្ឋានគតិយុត្តជាធរមាន និងទម្រង់នានាដែលមានសម្រាប់ដំណោះស្រាយ[58]។ ដោយហេតុថា ផ្នែកដែលពាក់ព័ន្ធផ្សេងៗនៃអញ្ញត្រកម្ម និងសំណើអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ត្រូវបានផ្អែកយ៉ាងខ្លាំងទៅលើការចោទប្រកាន់ផ្នែកអង្គហេតុដូចគ្នា ដូច្នេះ អញ្ញត្រកម្ម និងសំណើអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ត្រូវបានដាក់ដោយស្របតាមបទប្បញ្ញត្តិពីរផ្សេងគ្នា។ នៅក្នុងអញ្ញត្រកម្ម ជនជាប់ចោទតម្រូវឲ្យបង្ហាញថា ការចោទប្រកាន់ផ្នែកអង្គហេតុមានលក្ខណៈធ្ងន់ធ្ងរ ដែលតម្រូវឲ្យមានការបញ្ចប់ដំណើរការនីតិវិធី[59]។ នៅក្នុងសំណើអនុលោមតាមវិធាន ៣៥ របស់ខ្លួន ជនជាប់ចោទបានធ្វើការបង្ហាញថា ការចោទប្រកាន់ផ្នែកអង្គហេតុដូចគ្នាទាំងនេះ គឺជា"ហេតុផលដែលគួរឲ្យជឿបាន" ថាមានបុគ្គលម្នាក់បានជ្រៀត

---

[58] *សូមមើល* សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់លោក នួន ជា សុំបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៣៥ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ E82/1 កថាខណ្ឌ ២ (ដែលបញ្ជាក់ថា សំណើសុំអនុលោមតាមវិធាន ៣៥ ដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង "មិនបានលើកឡើងនូវការចោទប្រកាន់ថ្មីទេ ប៉ុន្តែគ្រាន់តែសំណូមពរឲ្យមានដំណោះស្រាយផ្សេងពីអ្វីដែលបានលើកឡើងនៅក្នុងអញ្ញត្រកម្ម [របស់ជនជាប់ចោទ]" (សេចក្តីបញ្ជាក់បន្ថែម)។

[59] *សូមមើល* សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៦-១៨។

ជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ។ លើសពីនេះទៀត ដោយខុសប្លែកពីអញ្ញត្រកម្ម[60] សំណើអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង តម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងផ្តួចផ្តើមការស៊ើបអង្កេតទៅលើករណីដែលត្រូវបានចោទប្រកាន់អំពីការជ្រៀតជ្រែក ដើម្បីការពារនូវសុចរិតភាពនៃដំណើរការនីតិវិធី ហើយ ក្នុងករណីសមស្របត្រូវចាត់វិធានការចាំបាច់ ដើម្បីស្តារឡើងវិញឱ្យមាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌[61]។

28. ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការអះអាងរបស់សហព្រះរាជអាជ្ញា[62] ដែលថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចយ៉ាងត្រឹមត្រូវនូវការចោទប្រកាន់ផ្នែកអង្គហេតុ ដែលទាក់ទិនដោយផ្ទាល់នឹងសំណុំរឿង ០០២ ដោយប្រកាសមិនទទួលយកការចោទប្រកាន់ដូចគ្នាទាំងនោះនៅក្នុងអញ្ញត្រកម្ម[63]នោះ ជាការលើកឡើងដោយភ័ន្តច្រឡំ។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយពុំបានផ្តល់នូវហេតុផលពេញលេញ ចំពោះការបដិសេធរបស់ខ្លួនទៅលើសំណើសុំអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ត្រង់ចំណុចដែលសំណើនេះទាក់ទិនទៅនឹងការចោទប្រកាន់ផ្នែកអង្គហេតុ ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសំណុំរឿង ០០២។ ទោះបីជាយ៉ាងណាក៏ដោយ ចំពោះហេតុផលដែលបានបញ្ជាក់ជូនខាងក្រោម កំហុសនេះពុំបានមោឃៈ សេចក្តីសម្រេចដែលរងការជំទាស់នេះឡើយ។

គ. <u>មូលដ្ឋានទីពីរ និងទីបីសម្រាប់បណ្តឹងសាទុក្ខ</u>

29. សមត្ថកិច្ចរបស់តុលាការទៅលើរឿងក្តីមួយនៅ អ.វ.ត.ក ត្រូវបានបែងចែកដោយយោងទៅលើដំណាក់កាលនៃរឿងក្តី។ សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះមានសមត្ថកិច្ចក្នុងដំណាក់កាលស៊ើបអង្កេត/មុនជំនុំជម្រះក្តី ដោយឡែកអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលមានសមត្ថកិច្ចក្នុងដំណាក់កាលជំនុំជម្រះក្តី និងដំណាក់កាលបណ្តឹងសាទុក្ខស្ថាពរ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើយកមកអនុវត្តឱ្យតឹងរ៉ឹងចំពោះពាក្យសុំអនុលោមតាមវិធាន

---

[60] អញ្ញត្រកម្ម កថាខណ្ឌ ៧៣(ខ) (ស្នើឱ្យចេញដីកាបង្គាប់ឱ្យរំលត់បណ្តឹងអាជ្ញា ឬជាជម្រើសមួយផ្សេងទៀត ពន្យារដំណើរការនីតិវិធីទៅលើ នួន ជា”)។

[61] សំណើអនុលោមតាមវិធាន ៣៥ កថាខណ្ឌ ៣២។

[62] សារណាតប កថាខណ្ឌ ១២, ២៨។

[63] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៧។

៣៥ នៃវិធានផ្ទៃក្នុង ការបែងចែកទូទៅនៃសមត្ថកិច្ចរបស់តុលាការនេះ នឹងធ្វើឲ្យប៉ះពាល់ដល់ការទទួលខុសត្រូវពេញលេញរបស់តុលាការ ដើម្បីធានានូវសុចរិតភាពនៃដំណើរការនីតិវិធី និងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌[64]។

30. ដូចដែលបានបង្កើតឡើងយ៉ាងជាក់លាក់នៅកម្រិតអន្តរជាតិ អំណាចក្នុងការដោះស្រាយពាក់ព័ន្ធជាមួយនឹងការប្រមាថតុលាការ ដែលជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ[65] ត្រូវបានប្រគល់ទៅឲ្យតុលាការដោយសារតែជាតួនាទីផ្នែកតុលាការ ហើយ"ចាំបាច់ណាស់ដើម្បីធានាថា ការអនុវត្តយុត្តាធិការរបស់តុលាការ ពុំត្រូវបានរារាំង ហើយតួនាទីមូលដ្ឋានរបស់តុលាការត្រូវបានការពារ"[66]។ ដូច្នេះ ជាការសំខាន់បំផុតដែលថា នៅពេញកិច្ចដំណើរការនីតិវិធីទាំងមូល

---

[64] *សូមមើល* សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សី ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D314/1/12 មតិយោបល់របស់ចៅក្រម Catherine Marchi-Uhel និងចៅក្រម Rowan Downing កថាខណ្ឌ ១០-១២។

[65] *សូមមើល* របាយការណ៍របស់គណៈកម្មាធិការស្តីអំពីការប្រមាថតុលាការ, UK Cmnd. 5794 (1974) (ដែលត្រូវបានគេហៅថា "របាយការណ៍របស់គណៈកម្មាធិការ Phillimore") ទំព័រ ២ កថាខណ្ឌ ១ ("ច្បាប់ ទាក់ទិននឹងការប្រមាថតុលាការបានអភិវឌ្ឍជាច្រើនទសវត្សរ៍មកហើយជាមធ្យោបាយមួយដែលតុលាការអាចយកមកអនុវត្តដើម្បីបង្ការ ឬដាក់ទណ្ឌកម្មដល់អំពើណាដែលមានចេតនារារាំង ធ្វើឲ្យប៉ះពាល់ ឬរំលោភលើកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ទាក់ទិនទៅនឹងករណីពិសេសមួយ ឬទូទៅ") ។ ទំព័រ ៧ កថាខណ្ឌ ១៤ (បែងចែកករណីនៃការប្រមាថជា "ការប្រមាថនៅក្នុងតុលាការ" និង "ការប្រមាថនៅក្រៅតុលាការ"។ ការប្រមាថនៅក្រៅតុលាការ រួមមានអំពើដែលទំនងជាជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការ ការសងសឹកទៅលើសាក្សី ឬភាគី ធ្វើឲ្យអាស្រូវដល់តុលាការ និងការមិនប្រតិបត្តិតាមសេចក្តីបង្គាប់របស់តុលាការ)។ *រឿងក្តី Johnson ទល់នឹង Grant* [1923] S.C. 789, ទំព័រ ៧៩០ ("បទល្មើស [ប្រមាថតុលាការ] រួមមាន នៅក្នុងការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ នៅក្នុងការរារាំង និងការធ្វើឲ្យខូចដល់ដំណើរការយុត្តិធម៌ [...]។ វាមិនមែនជាសេចក្តីថ្លៃថ្នូររបស់តុលាការឡើយដែលត្រូវបានប្រមាថ...។ វាគឺជាភាពឧត្តមបំផុតនៃច្បាប់ដែលត្រូវបានជំទាស់តវ៉ា")។ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Tadic*, IT-94-1-A-R77, "សាលដីកាលើការចោទប្រកាន់អំពីការប្រមាថប្រឆាំងនឹងអតីតមេធាវី Milan Vujin" អង្គជំនុំ ជម្រះតុលាការកំពូល ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ១៥, ១៧ (យល់ឃើញថា ទោះបីជាទស្សនាទាននៃ ការប្រមាថតុលាការបានអភិវឌ្ឍជានិម្មិតកម្មនៃច្បាប់អង់គ្លូសាក់សុង(common law) យ៉ាងណាក៏ដោយ ក៏ប្រព័ន្ធច្បាប់ស៊ីវិល(civil law) ជាច្រើនសម្រេចបាននូវលទ្ធផលស្រដៀងគ្នា តាមរយៈបទល្មើសដែលត្រូវបានកំណត់និយមន័យយ៉ាងចង្អៀតប្រឆាំងនឹងកិច្ចការរដ្ឋបាលរបស់តុលាការ) ជើងទំព័រ ១៦ (បង្ហាញថា របាយការណ៍របស់គណៈកម្មាធិការ Phillimore ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយជាការវាយតម្លៃយ៉ាងត្រឹមត្រូវមួយអំពីគោលបំណង និងវិសាលភាពច្បាប់នៃការប្រមាថតុលាការ)។

[66] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Beqaj*, IT-03-66-T-R77, "សាលក្រមលើការចោទប្រកាន់អំពីការប្រមាថតុលាការ" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ៩។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Aleksovski*, IT-95-14/1-AR77,

ចៅក្រមមានអំណាច "ចាត់វិធានការចាំបាច់ ដើម្បីធានានូវសុចរិតភាពនៃដំណើរការនីតិវិធី ដែលជាមូលដ្ឋានរក្សានូវការគោរពចំពោះយុត្តិធម៌"[67]។ ប្រសិនបើស្ថាប័នតុលាការរបស់ អ.វ.ត.ក មិនទទួលបាននូវបុព្វសិទ្ធិផ្តាច់មុខជាមូលដ្ឋាននេះទេ តុលាការមិនអាចធានាបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌សម្រាប់ជនជាប់ចោទឡើយ ហើយក៏មិនអាចបំពេញបេសកម្មរបស់ខ្លួនឱ្យបានយ៉ាងត្រឹមត្រូវនោះដែរ[68]។

---

"សាលដីកាលើបណ្តឹងសាទុក្ខរបស់ Anto Nobilo ប្រឆាំងនឹងការរកឃើញអំពីការប្រមាថតុលាការ" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១ កថាខណ្ឌ ៣០ (ដកស្រង់ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Tadic*, "សាលក្រម លើការចោទប្រកាន់អំពីការប្រមាថតុលាការប្រឆាំងនឹងអតីតមេធាវី Milan Vujin" កថាខណ្ឌ ១៣)។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Milosevic*, IT-02-54-A-R77.4, "សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំលើការប្រមាថដំណើរការនីតិវិធីរបស់ Kosta Bulatovic", អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ កថាខណ្ឌ ២១។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Blagojevic,* IT-02-60-T, "សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីឯករាជ្យ របស់ Vidoje Blagojevic ណែនាំដល់ប្រធានរដ្ឋបាលឱ្យតែងតាំងសហមេធាវីនាំមុខថ្មី" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ១១២ (បញ្ជាក់ថា វាគឺជាកាតព្វកិច្ចពេញលេញរបស់អង្គជំនុំជម្រះក្នុងការធានានូវការជំនុំ ជម្រះទោសប្រកបដោយយុត្តិធម៌ និងកិច្ចការរដ្ឋបាលដ៏ត្រឹមត្រូវរបស់តុលាការ ដោយពិចារណាចាត់វិធានការណាមួយដើម្បី ធានាថា "យុត្តិធម៌មិនត្រឹមតែត្រូវសម្រេចឱ្យបានប៉ុណ្ណោះទេ ប៉ុន្តែត្រូវតែបង្ហាញឱ្យឃើញថាមានយុត្តិធម៌ផងដែរ")។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Rwamakuba,* ICTR-98-44C-T, "សេចក្តីសម្រេចលើការផ្តល់សំណងសមស្រប" អង្គជំនុំជម្រះសាលា ដំបូង ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៧។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Karemera* និងអ្នកផ្សេងទៀត ICTR-98-44-PT, "សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីលើ Andre Rwamakuba និងការកែដីកាចោទប្រកាន់ មាត្រា ២០(៤) នៃលក្ខន្តិកៈ វិធាន ៨២(ខ) នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាង" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ២២។

[67] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Beqaj*, IT-03-66-T-R77, "សាលក្រមលើការចោទប្រកាន់អំពីការប្រមាថតុលាការ" អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ១៣។

[68] *សូមមើល រឿងក្តី Nuclear Tests (*ប្រទេសនូវែលសេឡង់ ទល់នឹង ប្រទេសបារាំង) សាលក្រម របាយការណ៍របស់ I.C.J. ឆ្នាំ ១៩៧៤ ទំព័រ ៤៦៣ កថាខណ្ឌ ២៣ ("តុលាការមានយុត្តាធិការពេញលេញ ដែលអាចឱ្យតុលាការចាត់វិធានការចាំបាច់ដើម្បីធានាថា ការអនុវត្តយុត្តាធិការរបស់ខ្លួនទៅលើអង្គសេចក្តី ប្រសិនបើត្រូវបានបង្កើតឡើង មិនត្រូវបានរារាំងឡើយ ហើយ [...] ថាតួនាទីផ្នែកតុលាការជាមូលដ្ឋានអាចត្រូវបានការពារ")។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Blaskic*, IT-95-14, "សាលដីកាលើសំណើរបស់សាធារណរដ្ឋក្រូអាស៊ី សុំឱ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៧" អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៧ កថាខណ្ឌ ៣៣, ៥៥ (ស្នើឡើងថា អំណាចពេញលេញមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងបេសកម្មដែលប្រគល់ទៅឱ្យតុលាការ និងមានគោលបំណងធានាថា តួនាទីជាមូលដ្ឋានរបស់តុលាការត្រូវបានបំពេញឱ្យបានពេញលេញ)។ *សូមមើល ផងដែរ រឿងក្តី Barayagwiza ទល់នឹង រដ្ឋអាជ្ញា* ICTR-97-

31. បញ្ហាដែលត្រូវលើកឡើងដោយអង្គជំនុំជម្រះតុលាការកំពូល គឺបញ្ហា ថាតើអំណាចណាមួយក្នុងចំណោមអំណាចដ៏ទូលំទូលាយនានា ដែលប្រគល់ឲ្យសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះនានាក្នុងការពារសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី ត្រូវតែធ្វើការសម្របសម្រួលទៅតាមប្រព័ន្ធនីតិវិធីរបស់ អ.វ.ត.ក នោះ។ ពាក់ព័ន្ធនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលឯកភាពជាទូទៅថា កិច្ចស៊ើបសួរដែលធ្វើឡើងដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង“អាចនឹងត្រូវបានអនុវត្តដោយប្រសិទ្ធភាព ... ដោយស្ថាប័នតុលាការដែលទទួលសំណុំរឿងនេះ”[69]។ ជាធម្មតា អង្គជំនុំជម្រះតុលាការកំពូលលើកឡើងថែមទៀតថា ជាធម្មតា រឿងរ៉ាវនៃការជ្រៀតជ្រែកដែលលេចឡើងនៅក្នុងមុនដំណាក់កាលជំនុំជម្រះត្រូវបានដោះស្រាយដោយស្ថាប័ននានានៃ អ.វ.ត.ក ដែលទទួលខុសត្រូវផ្នែកស៊ើបអង្កេត - ពោលគឺសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ។ ចំណែកឯរឿងរ៉ាវទាំងឡាយដែលកើតឡើងនៅដំណាក់កាលជំនុំជម្រះ ឬនៅដំណាក់កាលបណ្តឹងសាទុក្ខចុងក្រោយ ត្រូវស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល។ ទោះបីជាយ៉ាងណាក៏ដោយ មានកាលៈទេសៈតិចតួចដែលក្នុងនោះការទាមទារប្រសិទ្ធភាព និងភាពឥតលម្អៀង នៅក្នុងការពិនិត្យទៅលើការចោទប្រកាន់អំពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាល អាចមានអាទិភាពលើការបែងចែកជារួមនៃសមត្ថកិច្ចនៅក្នុងចំណោមស្ថាប័ន

---

19-AR72, “សាលដីកា” អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧៦ (“វាត្រូវបានគេទទួលស្គាល់ជាទូទៅថា តុលាការមានអំណាចត្រួតពិនិត្យដែលអាចត្រូវបានយកទៅប្រើដើម្បីផល ប្រយោជន៍យុត្តិធម៌ [...] ការប្រើប្រាស់អំណាចត្រួតពិនិត្យបែបនេះ មានមុខងារបីយ៉ាង ៖ ដើម្បីផ្តល់នូវសំណងចំពោះការរំលោភ សិទ្ធិជនជាប់ចោទ ដើម្បីរារាំងកុំឲ្យមានការប្រព្រឹត្តមិនត្រឹមត្រូវនៅពេលអនាគត និងដើម្បីលើកកម្ពស់នូវសុចរិតភាពនៃដំណើរការតុលាការ”)។ *រឿងក្តី សហរដ្ឋអាមេរិក ទល់នឹង Hasting*, 461 U.S. 499 [1983] ទំព័រ ៥០៥-៥០៦។ *រឿងក្តី Mesarosh ទល់នឹង សហរដ្ឋអាមេរិក*, វ៉ុល ៣៥២ សហរដ្ឋអាមេរិក ទំព័រ ១ [ ឆ្នាំ ១៩៥៦] (ដែលនៅក្នុងរឿងក្តីនោះ តុលាការកំពូលសហរដ្ឋអាមេរិកបាន បញ្ជាក់អំពីយុត្តាធិការត្រួតពិនិត្យរបស់ខ្លួនទៅលើកិច្ចដំណើរការនីតិវិធីរបស់តុលាការសហព័ន្ធ “ដើម្បីឲ្យដឹងថា ទន្លេនៃយុត្តិធម៌មិនត្រូវបានបំពុល (the waters of justice are not polluted)” (ដូចខាងលើ ទំព័រ ១៤)) ។ *រឿងក្តី McNabb និងអ្នកផ្សេងទៀត* ទល់នឹង សហរដ្ឋអាមេរិក, វ៉ុល ៣១៨ សហរដ្ឋអាមេរិក ទំព័រ ៣៣២ [ឆ្នាំ ១៩៤៣] (ដែលនៅក្នុងរឿងក្តីនោះ តុលាការកំពូលសហរដ្ឋអាមេរិក បានបញ្ជាក់អំពី “អំណាចត្រួតពិនិត្យរបស់ខ្លួនទៅលើកិច្ចការរដ្ឋបាលរបស់តុលាការព្រហ្មទណ្ឌ” (ដូចខាងលើ ទំព័រ ៣៤១) ដែលសំដៅទៅលើតួនាទីក្នុងការបង្កើត និងរក្សាបទដ្ឋានស្តីពីនីតិវិធី និងភ័ស្តុតាងប្រកបដោយអារ្យធម៌” (ដូចខាងលើ ទំព័រ ៣៤០) ដោយសារតួនាទីរបស់តុលាការនេះជា “តុលាការមានអំណាចត្រួតពិនិត្យចុងក្រោយ” (ដូចខាងលើ ទំព័រ ៣៤៧))។

[69] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១។

នានារបស់ អ.វ.ត.ក។ អង្គជំនុំជម្រះតុលាការកំពូលបន្តទៀតថា ស្ថាប័នណាមួយនៃអង្គជំនុំជម្រះដែលទទួលសំណុំរឿង - ដែលបច្ចុប្បន្នគឺជាអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២ - គ្មានជម្រើសអ្វីក្រៅតែពីការអនុវត្តអំណាចដែលមាន ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីស្របទៅនឹងបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ដោយមិនគិតថា រឿងរ៉ាវដែលត្រូវបានចោទប្រកាន់អំពីការជ្រៀតជ្រែកបានកើតឡើងនៅពេលណានោះទេ។

32. ទោះបីជាយ៉ាងនេះក្តី កាលៈទេសៈនៃបណ្តឹងសាទុក្ខនេះពុំតម្រូវឱ្យងាកចេញពីការបែងចែកជារួមនៃសមត្ថកិច្ចតុលាការនៅក្នុង អ.វ.ត.ក នោះឡើយ។ បើទោះជាមានការមើលរំលងនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ក៏ដោយ ក៏ការចោទប្រកាន់អង្គហេតុនានាដែលពាក់ព័ន្ធដោយផ្ទាល់នឹងសំណុំរឿង ០០២[70] ត្រូវបានប្តឹង និងពិចារណាយ៉ាងលម្អិតនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ[71]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់វិនិច្ឆ័យលើការចោទប្រកាន់ទាំងនេះម្តងហើយម្តងទៀត ដោយដើរតួជាតុលាការកំពូលពីលើស្ថាប័នតុលាការទាំងនេះឡើយ។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលយល់ស្របចំពោះការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើអំណះអំណាងដែលថា បញ្ហាដែលបានចេញផ្សាយដោយសារព័ត៌មាន ដែលបានលើកឡើងខាងលើ មានផលប៉ះពាល់ជាក់ស្តែងដល់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខខ្លួន។ បញ្ហាដែលពាក់ព័ន្ធនឹងសិទ្ធិរបស់ជនជាប់ចោទ គឺទាក់ទងទៅនឹងសាក្សីមួយចំនួនដែលស្នើឡើងដោយក្រុមមេធាវីការពារក្តីដែលសាក្សីទាំងនេះ មិនទាន់បានស្តាប់ចម្លើយនៅក្នុងដំណាក់កាលស៊ើបអង្កេត[72]។

---

[70] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣(ខ)(គ)(ឃ) និងកថាខណ្ឌ ៤។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ផ្ទុយពីការសន្និដ្ឋានរបស់ជនជាប់ចោទ សេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដូចបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខនេះ ត្រង់កថាខណ្ឌ ៣(គ) ពុំបានសំដៅលើសាក្សីសក្តានុពលជាក់លាក់ណាមួយ ដូចបានលើកឡើងយ៉ាងត្រូវដោយជនជាប់ចោទនៅក្នុងសំណើមុនៗរបស់ខ្លួននោះឡើយ (សំណើសុំ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ៣(ខ)។ សំណើសុំបើកកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារលេខ D254 កថាខណ្ឌ ៦)។

[71] សំណើសុំ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង លេខយោងជើងទំព័រ ២។ សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D314/1/12 កថាខណ្ឌ ១-១៧។

[72] *សូមមើល ឧទាហរណ៍* កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ឯកសារលេខ D301 ទំព័រ ១។ (ដែលពិចារណាថា វាចាំបាច់ត្រូវលាតត្រដាងការពិត ដោយត្រូវស្តាប់ចម្លើយព្រះមហាវីរក្សត្រ និងមន្ត្រីទាំង ៦ រូប) និងទំព័រ ៣ ទំព័រ ៤ (សម្រេចថា ដោយហេតុពិនិត្យឃើញថា “ការលំបាកធំធេង និងជាក់ស្តែង” ដែល “នៅក្នុងស្ថានភាព

បញ្ហានេះ ត្រូវតែសម្រេចនៅក្នុងអំឡុងពេលសវនាការនៃសំណុំរឿង ០០២ ដែលកំពុងបន្ត ដែលក្នុងសវនាការនេះ មានលទ្ធភាពជាច្រើនដែលបង្កើតឡើងទៅលើបញ្ហាដែលនាំឱ្យភស្តុតាងដោះបន្ទុក អាចត្រូវបានរារាំងដោយពុំត្រឹមត្រូវក្នុងពេលសវនាការ។ ឧទាហរណ៍ បញ្ហានេះអាស្រ័យទៅលើបញ្ហាថាតើ មេធាវីការពារក្តីទទួចស្នើសុំឱ្យមានភស្តុតាង ដែរ ឬយ៉ាងណា នៅក្នុងសំណើរបស់ខ្លួន និងថាតើ សំណើសុំនេះអាចទទួលយកបាន តាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណា និង ថាតើ អង្គហេតុដែលបានកើតចេញពីសក្ខីកម្ម រងការជំទាស់ ដែរ ឬយ៉ាងណា ឬ ថាតើ សាក្សីដែលបានកោះហៅនោះបង្ហាញខ្លួន ដែរ ឬយ៉ាងណា ហើយប្រសិនបើពុំបានធ្វើដូច្នេះវិញ ថាតើអង្គហេតុទទួលបានពីសាក្សីដែលបានកោះហៅមកផ្តល់សក្ខីកម្មនោះ អាចមានលក្ខណៈខុសគ្នា ដែរ ឬ យ៉ាងណា។

33. ដោយហេតុថាការលើកឡើងផ្នែកអង្គហេតុ គឺជាប់ពាក់ព័ន្ធជាចំបងជាមួយនឹងសំណុំរឿង ០០៣ និង ០០៤ ប៉ុន្តែ បានចោទឡើងថា មានការប៉ះពាល់ដោយប្រយោលលើភាពត្រឹមត្រូវនៅក្នុងសំណុំរឿង ០០២ វិញ[73]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បណ្តឹងសាទុក្ខនេះលើកឡើងនូវការជំទាស់ដែលថា ដោយសារការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលប្រឆាំងនឹងការចោទប្រកាន់របស់អយ្យការក្នុងសំណុំរឿង ០០៣ និង ០០៤ បង្ហាញឱ្យឃើញថា ជាការជ្រៀតជ្រែកប្រឆាំងនឹងជនជាប់ចោទក្នុងសំណុំរឿង ០០២[74] នោះ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ពុំមានការគាំទ្រណាមួយដល់អំណះអំណាងនេះទេ។ អង្គជំនុំជម្រះតុលាការកំពូលសំដៅទៅលើឆន្ទានុសិទ្ធិដ៏ទូលំទូលាយរបស់អង្គជំនុំជម្រះសាលាដំបូង ដែលជាស្ថាប័នសក្តិសមជាងគេបំផុត ក្នុងការវាយតម្លៃលើផលប៉ះពាល់នៃការចោទប្រកាន់ទាំងនេះលើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខខ្លួន។ ដោយហេតុថា មេធាវីការពារក្តី ពុំបានផ្តល់ការគាំទ្រដល់អំណះអំណាងរបស់ខ្លួន ដូច្នេះ ខ្លួនពុំបានបង្ហាញ

---

មួយនោះ អាចនឹងនាំឱ្យមានការពន្យារពេលដោយពុំសមហេតុផលនៅក្នុងការបញ្ចប់កិច្ចស៊ើបសួរ...វាជាការប្រសើរជាងនៅពេលទុកឱ្យអង្គជំនុំជម្រះសាលាដំបូង..សម្រេចថាតើត្រូវប្រើប្រាស់វិធានការចាប់បង្ខំដែរឬយ៉ាងណា")។ សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះបណ្តឹងឧទ្ធរណ៍របស់ អៀង សារី និង នួន ជា ស្តីពីការកោះហៅសាក្សីបន្ថែម ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០១០ ឯកសារលេខ D314/1/5 កថាខណ្ឌ ៥ (យល់ស្របជាមួយនឹងសហចៅក្រមស៊ើបអង្កេតអន្តរជាតិថា សក្ខីកម្មរបស់ព្រះមហាវីរក្សត្រ និងមន្ត្រីទាំង ៦ រូប "នឹងលាតត្រដាងការពិតពាក់ព័ន្ធនឹងអង្គហេតុដូចបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"។

[73] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣(ឃ) កថាខណ្ឌ ៥-៦ កថាខណ្ឌ ៩-១០។

[74] បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៧។

នូវកំហុសអង្គហេតុ ឬអង្គច្បាប់ ឬការភាន់ច្រឡំនៅក្នុងអនុវត្តឆន្ទានុសិទ្ធិដែលស្តែងឱ្យឃើញនោះឡើយ នៅក្នុងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការអះអាងទាំងឡាយពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤ ពុំមាន"ផលប៉ះពាល់ជាក់ស្តែង"[75] លើភាពត្រឹមត្រូវនៃសំណុំរឿង ០០២ នោះឡើយ[76]។

34. អង្គជំនុំជម្រះតុលាការកំពូល ក៏កត់សម្គាល់លើការលើកឡើងរបស់ជនជាប់ចោទអំពីហេតុការណ៍ សេចក្តីថ្លែងការណ៍ និងឯកសារដែលពុំមានចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅពេលខ្លួនចេញសេចក្តីសម្រេចដែលរងការជំទាស់នេះ។ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា នៅក្នុងពេលបច្ចុប្បន្ន ការចោទឡើងទាំងនេះកំពុងត្រូវបានវិនិច្ឆ័យដោយតុលាការជាតិ[77] ដែលក្រុមមេធាវីការពារក្តីបានស្នើសុំឱ្យមានការផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខតុលាការជាតិនេះ ហើយសង្កេតឃើញថា កិច្ចដំណើរការនីតិវិធីស្តីពីការខ្វែងយោបល់គ្នាជាច្រើន បានធ្វើឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ម្យ៉ាងវិញទៀត ការចោទឡើងទាំងនេះ គឺជាបញ្ហាចំបងចំពោះដំណើរការផ្លូវទូតរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ[78]។ លើសពីនេះ របាយការណ៍របស់តតិយជន

---

[75] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២១។

[76] ទោះបីជាយ៉ាងនេះក៏ដោយ ចំណុចនេះមិនគិតថា ចំពោះលក្ខខណ្ឌនៃវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដែលត្រូវបំពេញ ទង្វើនៃការជ្រៀតជ្រែកសាក្សី ឬ សាក្សីសក្តានុពល ត្រូវតែបង្ហាញលទ្ធផលរូបី ដូចបានបង្ហាញឱ្យឃើញយ៉ាងច្បាស់តាមរយៈសាលាក្តីអន្តរជាតិ (*រដ្ឋអាជ្ញា ទល់នឹង Beqaj* IT-03-66-T-R77 "សេចក្តីសម្រេចលើការចោទប្រកាន់អំពីការប្រមាថតុលាការ" អង្គជំនុំជម្រះសាលាដំបុង កថាខណ្ឌ ២១)។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Haraqija and Morina*, សំណុំរឿងលេខ IT-04-84-R77.4, "សាលក្រមស្តីពីការចោទឡើងនៃការប្រមាថតុលាការ", អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ ១៨១៨។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា និង អៀង សារី ប្រឆាំងនឹងដីកាកោះហៅសាក្សីរបស់ការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ D314/2/7 កថាខណ្ឌ ៣៨)។

[77] Abby Seiff និង Kuch Naren "មេធាវី នួន ជា តវ៉ាប្រឆាំងនឹងសេចក្តីសម្រេចលើការជ្រៀតជ្រែកតុលាការ" ឌឹឃែមបូឌាដេលី ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ២៤។

[78] "សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យសម្រាប់អគ្គលេខាធិការស្តីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា", ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២, គេហទំព័រ <http://www.un.org/sg/statements/index.asp?nid=5961> (ប្រកាសថា ក្នុងការជម្រុញឱ្យកាន់តែប្រសើរឡើងជាងមុននោះ អគ្គលេខាធិការអង្គការសហប្រជាជាតិ បានសម្រេចចាប់ផ្តើមនីតិវិធីជ្រើសរើសសហចៅក្រមស៊ើបអង្កេតថ្មី ហើយបានបញ្ជាក់ថា ការសហការ និងការជួយដ៏ពេញលេញពីសំណាក់រាជរដ្ឋាភិបាល មានសារៈសំខាន់ ហើយថា ទាក់ទងបញ្ហានេះ អង្គការសហប្រជាជាតិ នឹងនៅតែធ្វើការកត់សម្គាល់ដោយប្រុងប្រយ័ត្ន")។ "អង្គការសហប្រជាជាតិ បានបង្ហាញពីការព្រួយបារម្ភ នៅពេលដែលចៅក្រមទីពីរបានលាលែងចេញពីតុលាការជម្រះក្តីបទប្រល័យពូជសាសន៍នៅ

ដែលត្រូវបានលើកឡើងនៅក្នុងបណ្ដឹងសាទុក្ខ ភាគច្រើនមានលក្ខណៈទូទៅ ហើយពុំពាក់ព័ន្ធនឹងកាលៈទេសៈជាក់លាក់ណាមួយ ដែលអាចបណ្ដាលឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ នោះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលមិនធ្វើការពិចារណាចំពោះសារណារបស់ជនជាប់ចោទ ដែលធ្វើយុត្តិកម្មលើការជ្រៀតជ្រែកដោយស្វ័យប្រវត្តិស្ដីអំពីការកង្វះនូវភាពយុត្តិធម៌នៃសំណុំរឿង ០០២ ឡើយ។ ដោយហេតុថា ការអះអាងទាំងនេះជាប់ទាក់ទងដោយផ្ទាល់ទៅនឹងភាពត្រឹមត្រូវនៃសំណុំរឿង ០០៣ និង ០០៤ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសូមបញ្ជាក់សារជាថ្មីថា អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ដែលពុំទាន់បានទទួលរឿងក្ដីទាំងនេះនៅឡើយ ពុំមានសមត្ថកិច្ចធ្វើការប្រកាសណាមួយលើបញ្ហាទាំងនេះឡើយ។

ឃ. <u>មូលដ្ឋានទី៤ សម្រាប់បណ្ដឹងសាទុក្ខ</u>

35. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា មូលដ្ឋាននៃបណ្ដឹងសាទុក្ខមួយនេះ ពុំមានមូលដ្ឋានអង្គហេតុនៅក្នុងសេចក្ដីសម្រេចដែលរងការជំទាស់ ដែលពុំអាចត្រូវបានបកស្រាយដោយសមហេតុផលថា បានរារាំងភាគីមិនឲ្យស្នើសុំដល់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ អនុវត្តឆន្ទានុសិទ្ធិដើម្បីចាត់វិធានការ អនុលោមតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុងឡើយ។

---

កម្ពុជា", ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២, <<u>http://www.un.org/ apps/news/story.asp?NewsID=41578&Cr= Cambodia &Cr1</u>> (បញ្ជាក់ថា ស្ថានភាពនៅ អ.វ.ត.ក បន្ទាប់ពីការលាលែងរបស់ចៅក្រម Laurent Kasper-Ansermet គឺជា"ព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរ ហើយអង្គការសហប្រជាជាតិបាននឹងកំពុងតែពិនិត្យមើលដោយយកចិត្តទុកដាក់")។ "អ.វ.ត.ក: សេចក្ដីថ្លែងការណ៍រួមរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ", ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២, គេហទំព័រ <<u>http://www.cambodiaun.org/news/54-jan-2012/257-eccc-cambodia-un-joint-statement.html</u>> (បញ្ជាក់ថា ឧបនាយករដ្ឋមន្ត្រី សុខ អាន និង ឯកអគ្គរដ្ឋទូត David Scheffer, អ្នកជំនាញពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ, "មានបំណងបន្តកិច្ចពិភាក្សាយ៉ាងស្និទ្ធស្នាលរបស់ខ្លួន")។ "នៅកម្ពុជា, ប្រធានខាងផ្នែកច្បាប់របស់អង្គការសហប្រជាជាតិ បានប្រមានទៅលើការជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការ", *មជ្ឈមណ្ឌលសារព័ត៌មាន UN*, ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ , <http://www.un.org/apps/news/story.asp?NewsID=40124&Cr=cambodia&Cr1=> (បញ្ជាក់ថា ទីប្រឹក្សាច្បាប់ របស់ អង្គការសហប្រជាជាតិឈ្មោះ Patricia O'Brien បានជួបជាមួយឧបនាយករដ្ឋមន្ត្រី សុខ អាន ហើយបានទទួលឱ្យមានការ"គោរពដល់បូរណភាព និង ឯករាជភាពនៃដំណើរការនីតិវិធីរបស់តុលាការ")។

ង. បញ្ហាស្តីពីការបំពានគោលការណ៍រក្សាការសម្ងាត់ឯកសារ

36. ប្រសិនបើត្រូវបានបង្ហាញឲ្យឃើញហួសពីវិមតិសង្ស័យរួចហើយនោះ ការលាតត្រដាងឯកសារដែលត្រូវបានធ្វើចំណាត់ថ្នាក់រួចហើយ គឺជាបទល្មើសមួយប្រភេទ អនុលោមតាមវិធាន ៣៥(១)(ក) នៃវិធានផ្ទៃក្នុង ដែលអាចបណ្តាលឲ្យមានការដាក់ទណ្ឌកម្មស្របតាមច្បាប់កម្ពុជា[79] និង/ឬក៏ជាការកំហុសវិជ្ជាជីវៈរបស់មេធាវី[80]។ ដោយកត់សម្គាល់ឃើញអង្គហេតុនៃរឿងក្តីបច្ចុប្បន្ននេះ ដូចបានបញ្ជាក់ដោយក្រុមមេធាវីការពារក្តី[81] អង្គជំនុំជម្រះតុលាការកំពូលសូមរំឭកថា ចំណាត់ការសមស្របនោះ គឺគួរតែក្រុមមេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះដែលពាក់ព័ន្ធចេញផ្សាយជាឯកសារពាក់ព័ន្ធជាឯកសារសាធារណៈ[82]។

37. អង្គជំនុំជម្រះតុលាការកំពូលបានដឹងថា ក្រុមមេធាវីការពារក្តីបានឲ្យជាតម្រុយថា នាពេលខាងមុខខ្លួននឹងត្រៀមខ្លួនពុំគោរពតាមដោយចេតនាលើដីកានានា ទោះជាមានលក្ខណៈចងកាតព្វកិច្ចក៏ដោយ ហើយបានលើកឡើងថា ខ្លួន"នឹងបន្តបោះពុម្ពផ្សាយសារណារបស់ខ្លួនផ្ទាល់" ប្រសិនបើ យល់ឃើញថាស្របជាមួយនឹងច្បាប់កម្ពុជា និងស្របទៅតាមផលប្រយោជន៍របស់ នួន ជា[83]។ អង្គជំនុំជម្រះតុលាការកំពូលសូមគូសបញ្ជាក់ថា វាអាស្រ័យអង្គជំនុំជម្រះពាក់ព័ន្ធជាអ្នកសម្រេចថាតើឯកសារជាក់លាក់ណាមួយនៅក្នុងសំណុំរឿង ដែលត្រូវធ្វើចំណាត់ថ្នាក់ និងចាត់ទុកថាជាឯកសារសម្ងាត់ ឬសាធារណៈ ព្រមទាំងនឹងត្រូវកែប្រែចំណាត់ថ្នាក់បែបនេះឡើងវិញ[84]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសូមរំឭកដល់ក្រុមមេធាវីការពារក្តីថា ក្រុមមេធាវីការពារ ក្តីមានកាតព្វកិច្ចគោរពតាមដីកាសម្រេចរបស់តុលាការ និងការធ្វើចំណាត់ថ្នាក់លើឯកសារ[85] ហើយ

---

[79] វិធាន ៣៥(៤) នៃវិធានផ្ទៃក្នុង។

[80] វិធាន ៣៥(៥) និងវិធាន ៣៨ នៃវិធានផ្ទៃក្នុង។

[81] សារណាតប កថាខណ្ឌ ៦។

[82] សេចក្តីណែនាំអនុវត្តលេខ ០០៤/២០០៩៖ ចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿងត្រូវអនុម័ត ចុះថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០០៩ មាត្រា ៩.៣។

[83] សារណាតប កថាខណ្ឌ ៧។

[84] *សូមមើល រដ្ឋអាជ្ញា ទល់នឹង Jović* IT-95-14 & IT-95-14/2-R77 "សេចក្តីសម្រេច" អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦ កថាខណ្ឌ ២២។

[85] វិធាន ២២(៤) នៃវិធានផ្ទៃក្នុង (តម្រូវឲ្យមេធាវីនៅចំពោះមុខ អ.វ.ត.ក ត្រូវគោរពតាមសេចក្តីណែនាំអនុវត្ត អ.វ.ត.ក នៅក្នុងចំណោមឯកសារផ្សេងៗទៀត)។

ព្រមានក្រុមមេធាវីការពារក្តី កុំឲ្យលាតត្រដាងចេញផ្សាយព័ត៌មានសម្ងាត់ និងសម្ងាត់បំផុត ដោយគ្មានការអនុញ្ញាតជាបន្តទៀត។ ការលាតត្រដាងដោយគ្មានការអនុញ្ញាតបែបនេះ នឹងត្រូវបានចាត់វិធានការស្របតាមវិធាន ៣៥(២) និងវិធាន ៣៨ នៃវិធានផ្ទៃក្នុង[86]។

38. ពាក់ព័ន្ធនឹងការបំពានលើគោលការណ៍រក្សាការសម្ងាត់នៅក្នុងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចមិនផ្តួចផ្តើមកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៣៥ នៃវិធាន ផ្ទៃក្នុងឡើយ[87]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបន្ថែមទៀតថានឹងកែប្រែចំណាត់ថ្នាក់ឯកសារទាំងឡាយ ដែលបានដាក់បញ្ចូលនៅក្នុងបណ្តឹងសាទុក្ខភ្លាមៗនេះ៖ ឯកសារលេខ E116/1/1 ព្រមទាំងឯកសារភ្ជាប់លេខ E116/1/2, E116/1/2/1, E116/1/4 និង E116/1/5 ជាសាធារណៈ។

[86] *សូមមើល* សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តីសុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E115/3 កថាខណ្ឌ ៣៩ និងកថាខណ្ឌទី ៣ នៅក្នុងផ្នែកសម្រេចសេចក្តី។ ការព្រមានចំពោះការលាតត្រដាងព័ត៌មានសម្ងាត់ដោយគ្មានការអនុញ្ញាត ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារលេខ D314/1/11 ផ្នែកសម្រេចសេចក្តី។

[87] វិធាន ៣៥ នៃវិធានផ្ទៃក្នុង ផ្តល់ឆន្ទានុសិទ្ធិឲ្យសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ មានអំណាចសម្រេចលើការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាល ដូចបានបញ្ជាក់នៅក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃវិធាននេះដែលប្រើប្រាស់ ពាក្យថា "អាច"។ *សូមមើល រដ្ឋអាជ្ញា ទល់នឹង* *Nsengimana* ICTR-01-69-A/ICTR-2010-92 "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងដោយមិនត្រឹមត្រូវជាមួយនឹងសាក្សី" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១០ កថាខណ្ឌ ១៧ កថាខណ្ឌ ២២ (ដោយរកឃើញថា កិច្ចដំណើរការនីតិវិធីលើការប្រមាថតុលាការ គឺជាឆន្ទានុសិទ្ធិ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង "អាចបដិសេធមិនផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីនេះបាន ទោះបីជាមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការផ្តួចផ្តើមប្រឆាំងនឹងជនដែលប្រមាថតុលាការក៏ដោយ"។

## VI. ផ្នែកសម្រេចសេចក្តី

**យោងតាមសំអាងហេតុដូចខាងលើ** អង្គជំនុំជម្រះតុលាការកំពូល៖

**បដិសេធ**បណ្តឹងសាទុក្ខនេះ។

**ព្រមាន**ក្រុមមេធាវីការពារក្តី មិនឲ្យលាតត្រដាងដោយគ្មានការអនុញ្ញាតជាបន្តទៀត អំពីព័ត៌មានដែលត្រូវបានធ្វើចំណាត់ថ្នាក់រួចហើយ។

**សម្រេច**ធ្វើចំណាត់ថ្នាក់សារជាថ្មីលើឯកសារទាំងឡាយ ដែលបានលើកឡើងខាងលើ ឲ្យទៅជាឯកសារសាធារណៈ[88]។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**

[88] *សូមមើលខាងលើ* កថាខណ្ឌ ៣៨។